**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**
**គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ**
**ប្រឆាំងការសម្អាតប្រាក់ និង**
**ហិរញ្ញប្បទានភេរវកម្ម (គ.ស.ហ)**
លេខ ធ១២.០២០.០២៤ ប្រ.ក

# ប្រកាស

## ស្តីពី

## ការដាក់ទណ្ឌកម្មខាងវិន័យផ្នែកហិរញ្ញវត្ថុ ចំពោះបុគ្គលរាយការណ៍ ដែលមិនអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាស ឱ្យប្រើប្រាស់ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៩/៦៤២ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការតែតាំង **ឯកឧត្តម ជា ចាន់តូ** ទេសាភិបាល នៃធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ១៧៧ អនក្រ. បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកែប្រែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញសេចក្តីសម្រេចលេខ ៩៤ សសរ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧
- យោងតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០។

## សម្រេច



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងដាក់ចេញវិធានការទណ្ឌកម្មខាងវិន័យផ្នែកហិរញ្ញវត្ថុ ចំពោះបុគ្គលរាយការណ៍ ដែលពុំអនុវត្តតាមកាតព្វកិច្ចនានា ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ ២.- គោលដៅ**

វិធានការទណ្ឌកម្មខាងវិន័យផ្នែកហិរញ្ញវត្ថុ ចំពោះបុគ្គលរាយការណ៍ដែលមិនអនុវត្តតាមកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានគោលដៅជានាការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការប្រឆាំងសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ ៣.- វិសាលភាព**

វិធានការទណ្ឌកម្មខាងវិន័យផ្នែកហិរញ្ញវត្ថុនឹងត្រូវអនុវត្តចំពោះបុគ្គរាយការណ៍ ដែលស្ថិតក្រោមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលខកខានក្នុងការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤.-**

បុគ្គលរាយការណ៍ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យផ្នែកហិរញ្ញវត្ថុ ដូចមានកំណត់ ក្នុងឧបសម្ព័ន្ធដែលមានភ្ជាប់ជាមួយ នៅពេលរកឃើញថាមិនបានអនុវត្តកាតព្វកិច្ចមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម របស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា និងសេចក្តីណែនាំនិងបទបញ្ជាផ្សេងៗ របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

**ប្រការ ៥.-**

ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.-**

សមាជិកគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម សមាជិកក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លេខាធិការដ្ឋានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងបុគ្គលរាយការណ៍ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២០

**ទេសាភិបាល**
**និងជាប្រធាន គ.ស.ហ**

**ជា_ចាន់តូ**

**កន្លែងទទួល**
- បុគ្គលរាយការណ៍ដូចប្រការ ៤
- ឯកសារកាលប្បវត្តិ

**ចម្លងជូន**
- សមាជិកគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- សមាជិកក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយរាជកិច្ច"

## ឧបសម្ព័ន្ធនៃវិធានការទណ្ឌកម្មខាងវិន័យ

### ១. ការប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

| ល.រ | តម្រូវការ | ច្បាប់ និងប្រកាស | ចំនួនទឹកប្រាក់និងរូបភាពពិន័យ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ធនាគារពាណិជ្ជ<br>ធនាគារឯកទេស<br>គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ<br>ទទួលប្រាក់បញ្ញើ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | គ្រឹះស្ថានផ្តល់សេវាទូទាត់ | គ្រឹះស្ថានផ្សេងទៀត<br>ដែលស្ថិតក្រោម<br>អាណាព្យាបាលរបស់<br>ធនាគារជាតិនៃកម្ពុជា | ក្រុមហ៊ុន<br>អចលនទ្រព្យ<br>និង កាស៊ីណូ | មុខរបរនិងវិជ្ជាជីវៈ<br>មិនមែនហិរញ្ញវត្ថុ |
| ១ | ការអនុវត្តតាមអនុសាសន៍នៃរបាយការណ៍ចុះត្រួតពិនិត្យដល់ទីកន្លែង | • ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>មាត្រា ២២ | - លើកទីមួយ ២០លានរៀល<br>- លើកទីពីរ ៥០លាន រៀល<br>- លើកទីបី ១០០លាន រៀល<br>- បន្ទាប់ពីលើកទីបី ៥ភាគរយនៃដើមទុន អប្បបរមា រហូតដល់ អនុសាសន៍ទាំងអស់ត្រូវបានអនុវត្តពេញលេញ | - លើកទីមួយ ១លានរៀល<br>- លើកទីពីរ ៣លានរៀល<br>- លើកទីបី ៥លាន រៀល<br>- បន្ទាប់ពីលើកទីបី ៣០០ លានរៀលរហូតដល់អនុសាសន៍ទាំងអស់ត្រូវបានអនុវត្តពេញលេញ | - លើកទីមួយ ២លានរៀល<br>- លើកទីពីរ ៦លានរៀល<br>- លើកទីបី ១០លានរៀល<br>- បន្ទាប់ពីលើកទីបី ៤០០ លានរៀលរហូតដល់អនុសាសន៍ ទាំងអស់ត្រូវបានអនុវត្តពេញលេញ | - លើកទីមួយ ១លានរៀល<br>- លើកទីពីរ ៣លាន រៀល<br>- លើកទីបី ៥លានរៀល<br>- បន្ទាប់ពីលើកទីបី ចាប់ពី ៥លាន រៀល ដល់ដើមទុនអប្បបរមា រហូតដល់អនុសាសន៍ទាំងអស់ត្រូវបានអនុវត្តពេញលេញ | - លើកទីមួយ ២ លានរៀល<br>- លើកទីពីរ ៦ លានរៀល<br>- លើកទីបី ១០ លានរៀល<br>- បន្ទាប់ពីលើកទីបី ៤០០លាន រៀល ដល់ដើមទុនអប្បបរមា រហូតដល់ អនុសាសន៍ ទាំងអស់ត្រូវបានអនុវត្តពេញលេញ | - លើកទីមួយ ១លានរៀល<br>- លើកទីពីរ ៣លានរៀល<br>- លើកទីបី ៥លាន រៀល<br>- បន្ទាប់ពីលើកទីបី ៤០០ លានរៀលរហូតដល់អនុសាសន៍ទាំងអស់ត្រូវបានអនុវត្តពេញលេញ |
| ២ | ការត្រួតពិនិត្យផ្ទៃក្នុង | • ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>• មាត្រា១៦ | ៥០លានរៀល ដល់ ១៥ ពាន់លានរៀល | ២,៥លានរៀល ដល់ ៣០០លានរៀល | ៥ លានរៀល ដល់ ៤០០លានរៀល | ២,៥លានរៀល ដល់ ដើមទុនអប្បបរមា | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | • ប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>• ប្រការ ៣៤ និង៣៨ | | | | | | |
| | | • ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>មាត្រា ១៦<br>• ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រង របស់ធនាគារជាតិនៃកម្ពុជា<br>ប្រការ ៣១ និង ៣៥ | | | | | ៥លានរៀល ដល់ ដើមទុនអប្បបរមា | ២,៥ លានរៀល ដល់ ៤០០លានរៀល |
| ៣ | ការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | • ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>ប្រការ ៣ | ៥០លានរៀល ដល់ ១៥ ៣ន់លានរៀល | ២,៥លានរៀល ដល់ ៣០០លានរៀល | ៥ លានរៀល ដល់ ៤០០លានរៀល | ២,៥លានរៀល ដល់ ដើមទុនអប្បបរមា | | |
| | | • ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រង របស់ធនាគារជាតិនៃកម្ពុជា<br>ប្រការ ៤ | | | | | ៥ លានរៀល ដល់ ដើមទុនអប្បបរមា | ២,៥លានរៀល ដល់ ៤០០ លានរៀល |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤ | ការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន | • ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>មាត្រា ៧ - ១០<br>• ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>ប្រការ ៤ - ២៧ | ១០លានរៀល ដល់ ១៥ពាន់លានរៀល | ៥០ម៉ឺនរៀល ដល់ ៣០០លានរៀល | ១ លានរៀល ដល់ ៤០០លានរៀល | ៥០ម៉ឺនរៀល ដល់ ដើមទុនអប្បបរមា | | |
| | | • ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>មាត្រា ៧ - ១០<br>ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រង របស់ធនាគារជាតិនៃកម្ពុជាប្រការ ៥ - ២៤ | | | | | ១លានរៀល ដល់ ដើមទុនអប្បបរមា | ៥០ម៉ឺនរៀល ដល់ ៤០០លានរៀល |
| ៥ | ការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់និយោជិត | • ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>ប្រការ ៣៥ | ១០លានរៀល ដល់ ១៥ពាន់លានរៀល | ៥០ម៉ឺនរៀល ដល់ ៣០០លានរៀល | ១លានរៀល ដល់ ៤០០លានរៀល | ៥០ម៉ឺនរៀល ដល់ ដើមទុនអប្បបរមា | | |
| | | • ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រង របស់ធនាគារជាតិនៃកម្ពុជា<br>ប្រការ ៣២ | | | | | ១លានរៀល ដល់ ដើមទុនអប្បបរមា | ៥០ម៉ឺនរៀល ដល់ ៤០០លានរៀល |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៦ | ការរក្សាទុកឯកសារកត់ត្រា | • ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>មាត្រា ១១<br>• ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>ប្រការ ២២ - ២៤ | ២០លានរៀល ដល់ ១៥ ពាន់លានរៀល | ១ លានរៀល ដល់ ៣០០លានរៀល | ២លានរៀលដល់ ៤០០លានរៀល | ១លានរៀល ដល់ដើមទុនអប្បបរមា | | |
| | | • ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>មាត្រា ១១<br>• ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រង របស់ធនាគារជាតិនៃកម្ពុជា<br>ប្រការ ១៩ - ២១ | | | | | ២លានរៀលដល់ដើមទុនអប្បបរមា | ១លានរៀល ដល់ ៤០០លានរៀល |
| ៧ | ការតែងតាំង និងជូនដំណឹងពីការលាឈប់របស់មន្ត្រីប្រតិបត្តិ | • ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>មាត្រា ១៦ - ១៧<br>• ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>ប្រការ ៣៤ និង៣៦ | ១០លានរៀល ដល់ ១៥ ពាន់លានរៀល | ៥០ម៉ឺនរៀល ដល់ ៣០០លានរៀល | ១លាន រៀល ដល់ ៤០០លានរៀល | ៥០ម៉ឺនរៀល ដល់ដើមទុនអប្បបរមា | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | • ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>មាត្រា ១៦ - ១៧<br>• ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រង របស់ធនាគារជាតិនៃកម្ពុជា<br>ប្រការ ៣៣ | | | | | ១លានរៀលដល់ដើមទុនអប្បបរមា | ៥០ម៉ឺនរៀល ដល់ ៤០០លានរៀល |
| ៨ | ការបណ្តុះបណ្តាលបង្កើនការយល់ដឹងបុគ្គលិក | • ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>ប្រការ៣៧ | ៥០លានរៀល ដល់១៥ពាន់លានរៀល | ២,៥លានរៀល ដល់ ៣០០លានរៀល | ៥ លានរៀល ដល់ ៤០០លាន រៀល | ២,៥លានរៀល ដល់ ដើមទុនអប្បបរមា | | |
| | | • ប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រង របស់ធនាគារជាតិនៃកម្ពុជា<br>ប្រការ៣៤ | | | | | ៥លានរៀលដល់ដើមទុនអប្បបរមា | ២,៥លានរៀល ដល់ ៤០០លានរៀល |

## ២. កាលបរិច្ឆេទផ្តល់របាយការណ៍ និងព័ត៌មានផ្សេងៗ

| ល.រ | ប្រភេទឯកសារ | កាលកំណត់នៃការរាយការណ៍ | ចំនួនថ្ងៃដែលយឺតយ៉ាវ | ចំនួនទឹកប្រាក់និងរូបភាពពិន័យក្នុង១ថ្ងៃ | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | គ្រឹះស្ថានផ្តល់សេវាទូទាត់ | គ្រឹះស្ថានផ្សេងទៀតដែលស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា | ក្រុមហ៊ុនអចលនទ្រព្យ និង កាស៊ីណូ | មុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ |
| ១ | របាយការណ៍ប្រតិបត្តិការសាច់ប្រាក់[1] | អំឡុងពេល ១៤ ថ្ងៃក្រោយកាលបរិច្ឆេទនៃប្រតិបត្តិការ | - ១ - ៥ថ្ងៃ<br>- ៦-១០ថ្ងៃ<br>- ១១ -១៥ថ្ងៃ<br>- ចាប់ពី ១៦ថ្ងៃឡើងទៅ | - ១ លានរៀល<br>- ៧,៥ លានរៀល<br>- ១៥ លានរៀល<br>- ២០ លានរៀល និងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ | - ៥ ម៉ឺនរៀល<br>- ៣០ ម៉ឺនរៀល<br>- ៧០ ម៉ឺនរៀល<br>- ១ លានរៀល និងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ | - ១០ ម៉ឺនរៀល<br>- ៥០ ម៉ឺនរៀល<br>- ៨០ ម៉ឺនរៀល<br>- ១ លានរៀលនិងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ | - ៥ ម៉ឺនរៀល<br>- ១០ ម៉ឺនរៀល<br>- ២០ ម៉ឺនរៀល<br>- ៥០ ម៉ឺនរៀល និងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ | - ១ លានរៀល<br>- ៧,៥ លានរៀល<br>- ១៥ លានរៀល<br>- ២០ លានរៀល និងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ | - ៥ ម៉ឺនរៀល<br>- ៣០ ម៉ឺនរៀល<br>- ៧០ ម៉ឺនរៀល<br>- ១លានរៀល និងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ |
| ២ | របាយការណ៍ប្រតិបត្តិការសង្ស័យ[2] | ក្នុងអំឡុងពេល ២៤ ម៉ោង | | | | | | | |
| ៣ | របាយការណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យ ប្រចាំត្រីមាស | រៀងរាល់ថ្ងៃទី១៥ នៃខែទីមួយត្រីមាសបន្ទាប់ | | | | | | | |
| ៤ | របាយការណ៍លទ្ធផលវាយតម្លៃហានិភ័យសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | រៀងរាល់ដំណាច់ខែមិថុនាក្រោយកាលបរិច្ឆេទ ២ឆ្នាំនៃការវាយតម្លៃ | | | | | | | |
| ៥ | របាយការណ៍វឌ្ឍនភាពក្រោយការចុះត្រួតពិនិត្យដល់ទីកន្លែង | សប្តាហ៍ទីមួយ នៃត្រីមាសបន្ទាប់ | | | | | | | |

[1] ក្នុងមួយប្រតិបត្តិការ

[2] ក្នុងមួយរបាយការណ៍

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៦ | លិខិតឆ្លើយតប និងការផ្តល់ព័ត៌មាន | កាលបរិច្ឆេទដែលកំណត់ក្នុងលិខិត | - ១ - ៥ថ្ងៃ<br>- ៦ - ១០ថ្ងៃ<br>- ចាប់ពី ១១ថ្ងៃឡើងទៅ | - ៥០ ម៉ឺនរៀល<br>- ១ លានរៀល<br>- ២ លានរៀល និងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ | - ៥ ម៉ឺនរៀល<br>- ៣០ ម៉ឺនរៀល<br>- ៧០ ម៉ឺនរៀលនិងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរនិងមានការផ្សព្វផ្សាយជាសាធារណៈ | - ១០ ម៉ឺនរៀល<br>- ៥០ ម៉ឺនរៀល<br>- ១ លានរៀល និងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ | - ៥ ម៉ឺនរៀល<br>- ១០ ម៉ឺនរៀល<br>- ២០ ម៉ឺនរៀល និងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ | - ៥០ ម៉ឺនរៀល<br>- ១ លានរៀល<br>- ២ លានរៀល និងទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ | - ៥ ម៉ឺនរៀល<br>- ៣០ ម៉ឺនរៀល<br>- ៧០ ម៉ឺនរៀលនិង<br>- ទទួលរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងមានការផ្សព្វផ្សាយជាសាធារណៈ |